ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ អង្គារ ០២ រោច ខែ មិគសិរ ឆ្នាំ រោង ឆស័ក ព.ស ២៥៦៨*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ធ្នូ គ.ស. ២០២៤*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីជំនួបពិភាក្សាការងាររវាង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយឯកឧត្តម រីកាដូ ភូលីធី អនុប្រធានប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក នៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (International Finance Corporation - IFC)

នាព្រឹកថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០២៤, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិត-សភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុញ្ញាតទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម **រីកាដូ ភូលីធី (Riccardo Puliti)** អនុប្រធានប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក នៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (International Finance Corporation - IFC) ក្នុងឱកាសដែល **ឯកឧត្តមអនុប្រធាន** មានដំណើរទស្សនកិច្ចនៅកម្ពុជា ។

ជាមួយសេចក្តីសោមនស្សរីករាយ និងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តម **រីកាដូ ភូលីធី** និងសហការី ក្នុងឱកាសមកបំពេញបេសកកម្មការងារនៅប្រទេសកម្ពុជា, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានរំលឹកឡើងវិញនូវកិច្ចសហប្រតិបត្តិការដ៏ល្អរវាងរាជរដ្ឋាភិបាលកម្ពុជា និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ជាច្រើនទស្សវត្សន៍កន្លងមក និងបានវាយតម្លៃខ្ពស់ចំពោះការចូលរួមចំណែកដ៏សំខាន់របស់ IFC ដែលបានគាំទ្រកម្ពុជាក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ចាប់តាំងពីឆ្នាំ ២០០០ មក ទាំងក្នុងវិស័យហិរញ្ញវត្ថុ, កសិ-ពាណិជ្ជកម្ម, ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ភាពជាដៃគូរវាងរដ្ឋនិងឯកជន, និងវិស័យអប់រំ ដែលជាលទ្ធផលបានជួយបង្កើតឱកាសការងារថ្មី បង្កើនប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្រ ។

ឯកឧត្តម **រីកាដូ ភូលីធី** បានសម្តែងនូវការអរគុណចំពោះការស្វាគមន៍យ៉ាងកក់ក្តៅពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក្នុងដំណើរបេសកកម្មការងាររបស់ឯកឧត្តម ព្រមទាំងបានកោតសរសើរ និងវាយតម្លៃខ្ពស់ដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍប្រទេស ជាមួយនឹងការដាក់ចេញនូវគោលនយោបាយ ផែនការយុទ្ធសាស្រ្ត និងការវិនិយោគជាបន្តបន្ទាប់ រហូតមានការរីកចំរើនយ៉ាងឆាប់រហ័សដូចសព្វថ្ងៃ ។ **ឯកឧត្តមអនុប្រធាន** ក៏បានសម្តែងនូវការកោតសរសើរចំពោះការរីកចំរើនរបស់កម្ពុជាក្នុងការអភិវឌ្ឍថាមពលស្អាតដែលបច្ចុប្បន្នសម្រេចបាន ៥៨% នៃគោលដៅ ៧០% ព្រមទាំងបានគូសបញ្ជាក់អំពីការប្តេជ្ញា និងគោលជំហររបស់ IFC ក្នុងការបន្តគាំទ្រការអភិវឌ្ឍរបស់កម្ពុជា

តាមរយៈការជំរុញកិច្ចប្រតិបត្តិការឡើងវិញលើវិស័យអាទិភាពសំខាន់ៗជាអាទិ៍៖ វិស័យហិរញ្ញវត្ថុ, ហិរញ្ញប្បទានបៃតង, ឡូជីស្ទីក, ថាមពល, ការឆ្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុ ជាមួយនឹងការបន្តផ្តល់សេវាប្រឹក្សា និងការបណ្តុះបណ្តាល ដើម្បីរួមចំណែកជួយឱ្យកម្ពុជាសម្រេចបាននូវគោលដៅអភិវឌ្ឍប្រែក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានថ្លែងអំណរគុណចំពោះការប្តេជ្ញា និងគោលជំហររបស់ IFC ក្នុងការរួមចំណែកជំរុញការអភិវឌ្ឍរបស់កម្ពុជា និងបានជម្រាបជូនថា វិស័យជាអាទិភាពដែល IFC បានកំណត់ គឺពិតជាឆ្លើយតបទៅនឹងបញ្ហាកោណយុទ្ធសាស្ត្រទាំង ៥ នៃ**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** របស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ដែលស្ថិតក្រោមការដឹកនាំដ៏ត្រឹមត្រូវ, ស្វាហាប់ និងឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជា**នាយករដ្ឋមន្ត្រី** ។ ជាអាទិ៍, វិស័យហិរញ្ញវត្ថុ, ហេដ្ឋារចនាសម្ព័ន្ធ និងវិស័យឡូជីស្ទីក គឺជាវិស័យគន្លឹះ គាំទ្រការអនុវត្តកម្មវិធីជំរុញកំណើនរបស់រាជរដ្ឋាភិបាលសម្រាប់រយៈពេល ៤ ឆ្នាំខាងមុខ ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានស្នើសុំឱ្យសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ បន្តគាំទ្រកម្ពុជាទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីអាចឱ្យកម្ពុជាឈានឆ្ពោះទៅសម្រេចបានដោយជោគជ័យនូវចក្ខុ-វិស័យឆ្នាំ ២០៣០ និងឆ្នាំ ២០៥០ ។

ជាកិច្ចបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានជូនពរ **រីកាដូ ភូលីធី** ព្រមទាំងសហការីឱ្យទទួលបានជោគជ័យក្នុងដំណើរបេសកកម្មរបស់ខ្លួន និងជឿជាក់យ៉ាងមុតមាំថាបេសកកម្មការងារនេះ នឹងរួមចំណែកដល់ការបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិឱ្យកាន់តែរឹងមាំបន្ថែមទៀត ។